# របាយការណ៍ស្តីពីការចុះប្រមូលទិន្នន័យ និងវិភាគទិន្នន័យដើម្បីត្រៀមរៀបចំយុទ្ធនាការកម្ម វិធីពង្រឹងគុណភាពសេវា លើសេវាថែទាំបន្តនៃជំងឺអេដស៍នៅមន្ទីរពេទ្យបង្អែកខេត្តកោះកុង

ႽႽႽႽႽႽႽႽ

-យោងលិខិតលេខ : ០០៥៤ មជអសក ចុះ ថ្ងៃ ទី ២១ ខែ ឧសភា ឆ្នាំ ២០១០ របស់មជ្ឈមណ្ឌលជាតិ

-យោងលិខិតលេខ : ០០៥៥ មជអសក ចុះ ថ្ងៃ ទី ២១ ខែ ឧសភា ឆ្នាំ ២០១០ របស់មជ្ឈមណ្ឌលជាតិ

**I- កាលបរិច្ឆេទ:** ថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ២០១០ ទៅដល់ ថ្ងៃ ទី ០៥ ខែ មិថុនា ឆ្នាំ ២០១០

**II- ទីកន្លែង:** មន្ទីរពេទ្យបង្អែកខេត្តកោះកុង ខេត្តកោះកុង ។

**III- សមាសភាព:**

| | |
|---|---|
| ១-លោកវេជ្ជ. ខោល រ៉ោហិទ្ធិ | :អនុប្រធានផ្នែកស្រាវជ្រាវ |
| ២-លោកវេជ្ជ. ជន វិជ្ជា | :មន្រ្តីផ្នែកស្រាវជ្រាវ |
| ៣-លោកវេជ្ជ. គា ចិត្រា | :មន្រ្តីផ្នែកស្រាវជ្រាវ |
| ៤-លោកវេជ្ជ. សារុន សារាមុនី | :មន្រ្តីផ្នែកស្រាវជ្រាវ |
| ៥-លោកស្រីវេជ្ជ.សៅ សុគន្ធមីនី | :មន្រ្តីផ្នែកស្រាវជ្រាវ |
| ៦- លោក ម៉ម សុវត្ថា | :ប្រធានផ្នែកទិន្នន័យ |
| ៧-លោក ជា ចំណាន | :អនុប្រធានផ្នែកទិន្នន័យ |
| ៨- លោក ទឹង សុធា | :មន្រ្តីផ្នែកស្រាវជ្រាវ |
| ៩- លោក ពៅ សុភា | :មន្រ្តីផ្នែកស្រាវជ្រាវ ។ |

**IV- គោលបំណង:**

-ពិនិត្យមើលរួមគ្នានូវទិន្នន័យមួយចំនួនដែលទាក់ទងទៅនឹង Key Indicator របស់ CQI

-ស្វែងរកទិន្នន័យដែលទាក់ទងទៅនឹង Indicator និមួយៗ

-ពិភាក្សានិងផ្លាស់ប្តូរព័ត៌មានរវាងក្រុមបច្ចេកទេសថ្នាក់ជាតិ និងក្រុមការងារOI/ART

-បង្ហាញទិន្នន័យដែលរកឃើញទាក់ទិនទៅនឹង Indicator

-វិភាគទិន្នន័យដែលរកឃើញទាក់ទងទៅនឹង Indicator នីមួយៗ

-ពង្រឹងសមត្ថភាពក្រុមការងារ OI/ART និង ក្រុមមន្រ្តីពត៌មានអោយចេះធ្វើខ្លួនឯង

-ដោះស្រាយបញ្ហាមួយចំនួនដែលទាក់ទងទៅនឹង Indicator ដើម្បីអោយមានភាពប្រសើរឡើង

-ពិភាក្សាជារួមគ្នាជាតំណាង NGOsដែលបំរើការងារ CoC និងក្រុមការងារOI/ART

-ជ្រើសរើស Indicators ជាអាទិភាព វិភាគស្ថានភាព កំណត់បញ្ហា និងដំណោះស្រាយទៅតាមស្ថានភាពជាក់ស្តែង ព្រមទាំងលើកជាផែនការសកម្មភាពសំរាប់អនុវត្តរយៈពេល១២ខែខាងមុខ ។

**V-សកម្មភាព**

ក្រុមការងារបច្ចេកទេសរបស់មជ្ឈមណ្ឌលជាតិ បានជួបជាមួយលោកវេជ្ជ.ទៅ មុឹង អនុប្រធានមន្ទីរសុខាភិបាលខេត្តកោះកុង ដើម្បីជំរាបជូនពីគោលបំណងនៃការចុះប្រមូលទិន្នន័យនិងវិភាគទិន្នន័យដើម្បីត្រៀមរៀបចំយុទ្ធនាការកម្មវិធីពង្រឹងគុណភាពសេវា លើសេវាថែទាំបន្តនៃជំងឺអេដស៍នៅមន្ទីរពេទ្យបង្អែកខេត្តកោះកុង ។

ក្រុមការងារបច្ចេកទេសរបស់មជ្ឈមណ្ឌលជាតិ បានជួបនិងពិភាក្សាជាមួយ វេជ្ជ.ឡេង វេងសៃ ប្រធានកម្មវិធីអេដស៍ខេត្ត មន្ត្រីផ្នែកទិន្នន័យ និងលោកស្រីវេជ្ជ.ម៉ាត់លី ហៃ្សណុប ប្រធានមន្ទីរពេទ្យបង្អែកខេត្តកោះកុង លោកវេជ្ជ.ហៃ ឡៃសុន ប្រធានក្រុម OI/ART នៃមន្ទីរពេទ្យបង្អែកខេត្តកោះកុង ដើម្បីជំរាប់ជូនបនៃការចុះប្រមូលទិន្នន័យនិងវិភាគទិន្នន័យដើម្បីត្រៀមរៀបចំយុទ្ធនាការកម្មវិធីពង្រឹងគុណភាពសេវា លើសេវាថែទាំបន្តនៃជំងឺអេដស៍នៅមន្ទីរពេទ្យបង្អែកខេត្តកោះកុង ហើយក្រុមការងារបច្ចេកទេសរបស់មជ្ឈមណ្ឌលជាតិបានបែងចែកការងារគ្នាទៅតាមភារៈកិច្ចរៀង១ខ្លួនដើម្បីបង្គ្រប់Indicators ដែលមានការខ្វះខាត ។

ក្រុមការងារបច្ចេកទេសរបស់មជ្ឈមណ្ឌលជាតិ បានរៀបចំកិច្ចប្រជុំជាមួយជាក្រុមOI/ART, IT, Counselor, NGOs and PLHA ដើម្បីពិនិត្យមើលទិន្នន័យរបស់ Indacator នីមួយ១ទៅតាមត្រីមាសនៃឆ្នាំនីមួយ១ ។

ជាបន្តក្រុមការងារបច្ចេកទេសរបស់មជ្ឈមណ្ឌលជាតិ បានបង្ហាញនូវ Indicatorsទាំងអស់ ដើម្បីអោយក្រុមការងារថ្នាក់ខេត្តកំណត់នូវIndicatorsមួយណាដែលជាអាទិភាព ។

ជាបន្តទៀត ក្រុមការងារបច្ចេកទេសរបស់មជ្ឈមណ្ឌលជាតិ បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារOI/ART, Counselor, NGOs and PLHA ដោយលើកយកIndicator ទាំងអស់មកពិភាក្សា ដោយផ្អែកទៅលើក:

- **Importance ( សំខាន់ )**
- **Urgency ( បន្ទាន់ )**
- **Feasibility ( អាចធ្វើទៅបាន )**

## VI- <u>លទ្ធផល</u>

ជាលទ្ធផលក្រុមការងារបច្ចេកទេសរបស់មជ្ឈមណ្ឌលជាតិ និងក្រុមការងារOI/ART, Counselor, NGOs and PLHA សំរេចលើកយក**២** Indicator មកពិភាក្សា ដោយកំណត់បញ្ហា វិភាគបញ្ហា ដោះស្រាយបញ្ហា និងលើកផែនការសកម្មភាពសំរាប់អនុវត្តរយៈពេល១២ខែខាងមុខទៀត :

១-ភាគរយនៃអ្នកជំងឺមកពិនិត្យយឺត ហើយអស់ថ្នាំបំរុង (លើស៥ថ្ងៃ)

- **សំខាន់:១៦/១៦**
- **បន្ទាន់:១៦/១៦**
- **អាចធ្វើទៅបាន:១៦/១៦**

២-ភាគរយនៃអ្នកនៃអ្នកជំងឺដែលមាន CD4 តូចជាង២៥0 ឬ WHO stage 4 ដែលចាប់ផ្តើមប្រើថ្នាំប្រឆាំងមេរោគអេដស៍ (ក្នុងរយៈ ៦0ថ្ងៃ)

- **សំខាន់:១៦/១៦**
- **បន្ទាន់:១៦/១៦**
- **អាចធ្វើទៅបាន:១៦/១៦**

## ☛ <u>វិភាគបញ្ហា</u>


ភាគរយនៃអ្នកជំងឺមកទទួលថ្នាំយឺតដោយហួសថ្នាំបំរុងចំនួន៩ថ្ងៃ
អ្នកជំងឺ
-ឆ្ងាយពេក ភូមិសាស្ត្រមិនអំណោយផល ភាគច្រើនជាអ្នកនេសាទចរុទូកយូរ អ្នកជំងឺមិនចូលក្រុម HBC
-ចំណាកស្រុក (ទៅរកស៊ីនៅថៃ) ខ្វះថវិការធ្វើដំណើរ ឈឺធ្ងន់ពេក (គ្មានសាច់ញាតិជូនមក)
-អ្នកជំងឺគ្មានការទទួលខុសត្រូវខ្លួនឯង គ្មានចំណេះដឹង មានការភ័យខ្លាចនៅពេលហួសពេលណាត់
ប្រព័ន្ធ
-HBC (only RACHA) មានតែ៦ក្រុម ធ្វើសកម្មភាពនៅមានកិរិត មិនអាចគ្របដណ្តប់អ្នកជំងឺអស់
-ទំនាក់ទំនងរវាង MMM , counselor ,IT , Dr., pharmacist ,PAO និង HBC នៅមានកំរិត
- ខ្វះមធ្យោបាយសំរាប់ទំនាក់ទំនងជាមួយនឹងអ្នកជំងឺ
- មិនទាន់មានប្រព័ន្ធណាត់អ្នកជំងឺច្បាស់លាស់ (IT មិនបានបញ្ជូនបញ្ជីឈ្មោះអ្នកជំងឺដែលបានណាត់មកអោយគ្រូពេទ្យ)
-ខ្វះខាតសំភារៈការិយាល័យ និង សំភារៈពេទ្យ ខ្វះខាត computer
អ្នកផ្តល់សេវា
-HBC មិនអាចទាក់ទងអ្នកជំងឺបានដោយសា (ភ្លៀង អ្នកជំងឺនៅឆ្ងាយពេក... ) ថវិការផ្តល់ដល់អ្នកជំងឺនៅមានកំរិត ក្រុម HBC មានតិច
-ខ្វះគ្រូពេទ្យ
-អ្នកផ្តល់ប្រឹក្សាពន្យល់អ្នកជំងឺនៅមានការខ្វះខាត /នៅមានកំរិត
-អ្នកជំងឺច្រើនពេកដោយសារខ្វះធនធានមនុស្ស (គ្រូពេទ្យ )/ ថវិការឧបត្ថម្ភមានចំនួនតិចតួច


ភាគរយនៃអ្នកជំងឺដែលសមស្របនឹងទទួល ARV ក្នុងរយៈពេល ៦០ថ្ងៃ
អ្នកជំងឺ
-អ្នកជំងឺនៅឆ្ងាយ ខ្វះទំនាក់ទំនង ខ្វះអ្នកគាំទ្រពីគ្រួសាររបស់គាត់ ចំណាកស្រុក (នៅស្រុកថៃ)
-អត់ចេះអក្សរ ខ្វះមធ្យោបាយធ្វើដំណើរ មានបញ្ហាផ្លូវចិត្ត
-អ្នកជំងឺមិនគោរពការណាត់
-មានជំងឺឱកាសនិយមច្រើន (របេង...) ផ្ទះឆ្ងាយ គ្មានថវិការគ្រប់គ្រាន់សំរាប់ធ្វើដំណើរ
ប្រព័ន្ធ
-ទុកដាក់ឯកសារមិនត្រឹមត្រូវ (ទុកចោល មិនបញ្ជូន)
-ទទួលលទ្ធផលយឺតមកពី NIPH
- មិនទាន់មានប្រព័ន្ធបញ្ជូនពត៌មាន សំរាប់អ្នកជំងឺ OI follow up ដែលមាន CD4<250
-ទំនាកទំនងរវាង គ្រូពេទ្យ អ្នកផ្តល់ប្រឹក្សា និង MMM នៅមានកំរិត
-ខ្វះ Computer
អ្នកផ្តល់សេវា
-ការផ្តល់ប្រឹក្សានៅមានកំរិត
-អ្នកជំងឺច្រើនពេក គ្រូពេទ្យតិច ទៅ
- កង្វះ HBC

## ☛ ដំណោះស្រាយ







## VII- សកម្មភាពសំរាប់រយ:ពេល ១២ខែទៅខាងមុខ

## VII- សកម្មភាពសំរាប់រយៈពេល ១២ខែទៅខាងមុខ

ជាបន្តក្រុមការងារOI/ART,Counselor, NGOs and PLHA បានរៀបចំជាផែនការសកម្មភាពសំរាប់អនុវត្តក្នុងរយៈពេល ១២ខែខាងមុខ (ដូចមាននៅតារាងខាងក្រោយ) ។

ក្រុមការងារបច្ចេកទេសនៃមជ្ឈមណ្ឌលជាតិ បានថ្លែងនូវការកោតសរសើរចំពោះ ការខិតខំប្រឹងប្រែងរបស់លោកប្រធានមន្ទីរសុខាភិបាលកោះកុង ប្រធានកម្មវិធីអេដស៍ខេត្ត ប្រធានក្រុមការងារOI/ART នៃមន្ទីរពេទ្យបង្អែកខេត្តកោះកុង និងមន្ត្រីផ្នែកទិន្នន័យ ដែលបានសហការល្អ និងចំណាយពេលវេលាដ៏មានតំលៃអោយក្រុមការងារបច្ចេកទេសយើង បានស្វែងរកទិន្នន័យតាមតម្រូវការ ដើម្បីរៀបចំផែនការសកម្មភាពក្នុងគោលបំណងពង្រឹងគុណភាពសេវាលើសេវាថែទាំ បន្តនៃជំងឺអេដស៍ នៅមន្ទីរពេទ្យបង្អែកខេត្តកោះកុង អោយមានភាពប្រសើរឡើង ។

ភ្នំពេញ, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០

| បានឃើញ និងឯកភាព<br>ប្រធានមជ្ឈមណ្ឌលជាតិ | ពិនិត្យ | អ្នកសរសេររបាយការណ៍ |
| --- | --- | --- |
| វេជ្ជ មាន_ឈីវុន | បណ្ឌិត.សាផុន វឌ្ឍនៈ | វេជ្ជ. ជន វិជ្ជា |